# ធម្មយុត្តិកប្រវត្តិ

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

ផ្សាយចេញពី

សំឃបណ្ណាល័យ វត្តបទុមវតីរាជវរារាម

ព្រះនិពន្ធលេខ ៤៧

នៃសម្តេចព្រះសង្ឃនាយក គណធម្មយុត្តិកនិកាយ

រោងពុម្ពអ្នកខ្ញុំ ប៊ូតរោស៊ាក

ព.ស. ២៥០៣ គ.ស. ១៩៦០

២៦០.
៨៨

២៦០.៤៤

# ធម្មយុត្តិកប្រវត្តិ

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
៤២៥១/៤៤

ផ្សាយចេញពី

សំឃបណ្ណាល័យ វត្តបទុមវតីរាជវរារាម

៣២៥៨

ក្រោមកិច្ចឧបត្ថម្ភ

នៃសម្តេចព្រះសង្ឃនាយក គណធម្មយុត្តិកនិកាយ

បោះពុម្ពគង់ឆ្នាំជូតទោស័ក

ព.ស. ២៥០៣ គ.ស. ១៩៦០

# ពាក្យប្រារព្ធ

រឿងធម្មយុត្តិកប្រវត្តិនេះ កើតឡើងដោយពួកពុទ្ធបរិស័ទខាងគណៈធម្មយុត្តិកនិកាយ មានប្រាថ្នាចង់រក្សាទុកនូវកេរ្តិ៍មត៌កនៃបុព្វាចារ្យទាំងឡាយរបស់ខ្លួនឲ្យបានគង់វង្ស ដើម្បីឲ្យបានជ្រាបទូទៅដល់ពុទ្ធបរិស័ទគ្រប់ប្រភេទ អំពីសេចក្ដីពិតនៃគណៈនេះ, ទើបបានប្រមូលរឿងរ៉ាវតាមឯកសារផ្សេងៗ យកមកចងក្រងជាលំដាប់រឿង បោះពុម្ពជាសៀវភៅនេះឡើង ដោយបំព្រួញ ឲ្យឈ្មោះថា «ធម្មយុត្តិកប្រវត្តិ» ដើម្បីចែកផ្សាយក្នុងឱកាសនៃការធ្វើបុណ្យរំលឹកដល់ព្រះគុណសម្ដេច ព្រះសុគន្ធាសំយព ជាគណាធិបតី បញ្ញាសីលោ-ចាំង, ដែលព្រះអង្គបាននាំយកលទ្ធិពុទ្ធសាសនាសំរាប់គណៈធម្មយុត្ត មកផ្សាយឲ្យបានជ្រួតជ្រាបក្នុងប្រទេសកម្ពុជាជាដំបូងបង្អស់ជាប់តវង្សរហូតមកដល់សព្វថ្ងៃនេះ, ឥតដែលមានវិបត្តិប្រែប្រួលអ្វីឡើយ ដោយព្រះបរមរាជូបត្ថម្ភនៃព្រះករុណាព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី (ព្រះអង្គឌួង) ដរាបមកដល់ព្រះករុណាព្រះមហាកាញ្ចនកោដ្ឋ ។

យើងសូមឧទ្ទិសនូវមហាកុសល ថ្វាយចំពោះសម្ដេចព្រះសុគន្ធាសំយ-ពជាគណាធិបតី និងថ្វាយចំពោះព្រះរាជាគ្រប់ព្រះអង្គ, ដែលទ្រង់សោយ

ព្រះទិវង្គតទៅកាន់បរលោកនាយ សូមទ្រង់បានប្រកបដោយព្រះបរមសុខ ដរាបលុះសម្រេចព្រះនិព្វានកុំបីឃ្លាតឡើយ ។

ម្យ៉ាងទៀត យើងសូមអភ័យ អំពីសំណាក់លោកអ្នកចេះដឹងទាំងឡាយ ក្រែងមានការខុសឆ្គងពាក្យពេចន៍ឬអក្ខរាវិរុទ្ធត្រង់ណា សូមមេត្តាកែតម្រូវឲ្យបានផង ។

ក្រុមពុទ្ធបរិស័ទ

# ព្រះរាជប្រវត្តិ

## នៃព្រះបាទសម្តេចព្រះចមក្លៅព្រះចៅប្រទេសថៃ (១)

ព្រះបាទសម្តេចព្រះចមក្លៅ ទ្រង់ប្រសូតនៅថ្ងៃ៥ ១៥ ១១ ឆ្នាំជូត ឆស័ក ព.ស. ២៣៤៧ គ.ស. ១៨០៤ ម.ស. ១៧២៦ ច.ស. ១១៦៦ ត្រូវត្រង់ថ្ងៃមហាបវារណាចេញវស្សា នៅទីព្រះបរមរាជវាំងក្រុងធនបុរី ព្រះបាទសម្តេចព្រះឡឹតឡានភាល័យ រជ្ជកាលទី២នៃព្រះបរមរាជវង្សចក្រី ជាព្រះបរមរាជបិតា សម្តេចព្រះស្រីសុរិយេន្ទ្រា ជាព្រះបរមរាជជននី ។

ព្រះបាទសម្តេចព្រះចមក្លៅបានព្រះជន្ម៩ឆ្នាំ បានតាំងព្រះនាមជាព្រះចៅហ្វាមកុដរាជកុមារ ទ្រង់បានសិក្សាអក្សរសាស្ត្រនិងវិជ្ជាការផ្សេងៗខាងផ្លូវលោក លុះដល់ព្រះជន្ម១៤ឆ្នាំ ទ្រង់ព្រះផ្នួសជាសាមណេរក្នុងវត្តព្រះស្រីរតនសាស្តារាម សម្តេចព្រះសង្ឃរាជ (មី) ជាព្រះឧបជ្ឈាយ៍ សម្តេច ព្រះញាណសំវរ (សុខ) វត្តរាជសិទ្ធារាមជាព្រះអាចារ្យ លុះទ្រង់ព្រះផ្នួសស្រេចហើយស្តេចទៅគង់នៅវត្តមហាធាតុ លុះដល់ចេញវស្សា ទ្រង់លាចាកព្រះផ្នួសវិញ បានតាំងជាអធិបតីក្រុមមហាតឡ្លិក ។

លុះដល់ថ្ងៃ៤ ១២ ៨ ឆ្នាំវកឆស័ក ព.ស. ២៣៦៧ គ.ស. ១៨២៤

១– ប្រែចាកច្បាប់ព្រះរាជពង្សាវតារថៃ ក្រុងរតនកោសិន្ទ្ររជ្ជកាលទី ២ តាំងពីទំព័រលេខ ២២៦ ។ល។

ម.ស.១៧៤៦ ច.ស. ១១៨៦ សម្តេចព្រះចមក្សត្រព្រះជន្ម២១ ឆ្នាំ ទ្រង់បានបព្វជ្ជាឧបសម្បទជាភិក្ខុ ក្នុងវត្តព្រះស្រីរតនសាស្តារាម ហើយស្តេចយាងទៅគង់នៅវត្តសម៉ាយ ដែលផ្លាស់នាមថ្មីហៅថា "វត្តពជាធិពសន៍" ទ្រង់ព្រះផ្នួសបាន ១៥ ថ្ងៃ ព្រះបាទសម្តេចព្រះពុទ្ធឡើតឡានកាល័យ ជាព្រះបរមរាជបិតា ទ្រង់ទិវង្គតនៅថ្ងៃ ៤ ១១ ៨ ឆ្នាំវកឆស័កនោះ ។ ឯពជសម្បត្តិថ្វាយព្រះបាទសម្តេចព្រះណាងក្សត្រគ្រប់គ្រងតមក ។

សម្តេចព្រះចមក្សត្រ កាលទ្រង់ព្រះផ្នួសជាភិក្ខុស្រេចហើយ គង់ចាំវស្សានៅវត្តពជាធិពសន៍នោះ ទ្រង់សង្កេតឃើញសេចក្តីប្រតិបត្តិរបស់ភិក្ខុសាមណេរក្នុងអាវាសនោះ មិនស្អាតបរិសុទ្ធល្អមិនត្រឹមត្រូវតាមធម៌វិន័យ ប្រព្រឹត្តតែតាមលទ្ធិអាចារ្យពីបុរាណ ដែលប្រកាន់ខុសធម៌វិន័យ ទើបទ្រង់ស្តេចចេញពីវត្តនោះទៅគង់នៅវត្តមហាធាតុវិញ ។ គ្រានោះសម្តេចទ្រង់តាំងព្យាយាមសិក្សាព្រះធម្មវិន័យ ព្រះត្រៃបិដកចេះដឹងយល់ផ្លូវខុសត្រូវខ្លះហើយ ទ្រង់បានសង្កេតឃើញភិក្ខុសាមណេរក្នុងវត្តនោះ ប្រព្រឹត្តអនាចារខុសធម៌វិន័យជាច្រើនប្រការ រូបខ្លះទេសនាមហាជាតក៍ស្លូតជាបទភ្លេងមានក្លែងចាំទទួល រូបខ្លះស៊ីឈ្នួលគេសូត្រម៉ាឡៃ រូបខ្លះចេញកំអួតគនឹងអាយ៉ៃយីកេរ រូបខ្លះធ្វើជាជាងទង, ជាងគំនូរ, ជាងស៊ុម៉ង់ត៍

បាយអលក់យកចំណេញ រូបខ្លះបួមបួសព្រឹកសឹកល្ងាចលេងស្រី បរិភោគបាយល្ងាចកាន់ប្រាក់មាស ទិញទំនិញដោយផ្សារតថ្លៃជាមួយអ្នកលក់ដោយខ្លួនឯង ឆាន់គោជនាហារ ឬភេសជ្ជៈដែលគេពុំបានប្រគេន ធ្វើពេទ្យហ៊ា ។ លុះសម្តេចព្រះចមក្សត្រទ្រង់ជ្រាបដូច្នេះហើយ ព្រះអង្គស្តុកព្រះទ័យណាស់ ល្បងយល់ថា ការដែលកើតសេចក្តីប្រតិបត្តិអាក្រក់ខុសធម៌វិន័យយ៉ាងនេះ កើតមានមកតាំងពីកងទ័ពភូមាចូលលុកលុយវាយក្រុងស្រីអយុធ្យា ក្នុង ព.ស. ១៦០៥ គ.ស ១០៦២ ម.ស ៩៨៤ ច.ស. ៤២៦ ។ សឹកសង្គ្រាមសៀមនឹងភូមាគ្រានោះ ជាហេតុបណ្តាលឲ្យភិក្ខុសាមណេរជាតិសៀមនាំគ្នាធ្វើទាហាន ចេញម៉្យាងទៀតទ័ពភូមាតាំងគេចសមណៈ ព្រះអង្គជ្រាបដូច្នេះហើយ ក៏ទ្រង់សន្និដ្ឋានក្នុងព្រះទ័យថា អាត្មាអញបួសនេះពិតជាខុសចាកព្រះធម៌វិន័យពុទ្ធបញ្ញត្តិ មិនគួរទ្រាំសម្ងំប្រព្រឹត្តបែបនេះតទៅទៀតឡើយ គួរតែរើរកផ្លូវបព្វជ្ជាឧបស-ម្បទឲ្យបានត្រឹមត្រូវ តាមពុទ្ធបញ្ញត្តិឲ្យសមតាមគន្លងព្រះអរិយៈ ដែលលោកបានធ្វើសង្គាយនាលើកព្រះពុទ្ធសាសនា ឲ្យបានរុងរឿងជាដរាបមក ។ល។

សម្តេចព្រះចមក្សត្រទ្រង់ព្រួយព្រះទ័យ នឹងព្រះពុទ្ធសាសនាណាស់

នៅថ្ងៃឧបោសថមួយ ព្រះអង្គយាងចូលបន្ទប់សម្រាប់ផ្ទំទ្រង់រៀបតាក់តែងគ្រឿងសក្ការបូជាថ្វាយព្រះពុទ្ធជាម្ចាស់នឹងបូជាគ្រប់ទិស រួចហើយទ្រង់ថ្វាយបង្គំរលឹកគុណព្រះរតនត្រ័យ លុះចប់ហើយទើបទ្រង់តាំងសត្យាធិដ្ឋានថា « ខ្ញុំព្រះករុណាសូមឧទ្ទិសចំពោះព្រះពុទ្ធជាម្ចាស់ ព្រមទាំងទេពត្តាទេវតាទាំងឡាយ ដ្បិតកាលដែលខ្ញុំចេញមកបួសដោយចិត្តជ្រះថ្លាចំពោះព្រះរតនត្រ័យ ខ្ញុំមិនបានបួសដោយប្រាថ្នាតាមិសណាមួយមានលាភយស នឹងសេចក្ដីសរសើរជាដើមសោះឡើយ ។ ហេតុនេះខ្ញុំចង់ដឹងថា បើពូជពង្សសមណភេទអ្នកបួសជាប់តៗ គ្នាមកតាំងអំពីគ្រាព្រះបរមសាស្ដាគង់ព្រះជន្មនៅឡើយ បើមានប្រតិស្ឋាននៅក្នុងប្រទេសណាទិសណា សូមឲ្យខ្ញុំព្រះករុណាបានជួបប្រទះឬមួយ បានឮដំណឹងរបស់ពូជសមណៈនោះក្នុងរវាង ៣ ថ្ងៃ ឬ ៧ ថ្ងៃ កុំខាន បើខ្ញុំព្រះករុណាមិនបានឮដំណឹងនោះទេ ខ្ញុំព្រះករុណានឹងសន្និដ្ឋានទុកក្នុងចិត្តជាស្រេចថា ពូជសមណៈដែលជាប់តមកពីព្រះសម្មាសម្ពុទ្ធនោះ មុខជាបាត់សាបសូន្យអស់រលីងហើយ ខ្ញុំព្រះករុណានឹងលាចាកសិក្ខាបទទៅជាគ្រហស្ថរក្សាសីល ៨ វិញប្រសើរជាង ។

លុះគន់ពីពេលដែលទ្រង់អធិដ្ឋាននោះមក បានតែ ៣ ថ្ងៃប៉ុណ្ណោះ

ស្រាប់តែមានព្រះថេររាមញ្ញវង្ស ១អង្គព្រះនាមសុមេធាចារ្យ ជាពហូស្សូត្រ ឈ្លាសវៃក្នុងព្រះវិន័យ លោកចេះចាំពុទ្ធវចនស្ទាត់ ទាំងយល់ច្បាស់ក្នុង អត្ថវិធី បានឧបសម្បទក្នុងសំណាក់ នៃព្រះឧបជ្ឈាយ៍ដែលជាពូជ សមណៈជាប់តគ្នាមកអំពីព្រះអនុរុទ្ធមហាថេរ ក្នុងវិហារសីមាព្រះអរិយៈ ដែលតាំងខ្ជាប់នៅស្រុកមន មិនដែលវិបត្តិប្រែប្រួលឡើយជាប់តគ្នាមក រហូតដល់ព្រះឧបជ្ឈាយ៍របស់ព្រះសុមេធាចារ្យនេះ ចំនួន ៨៨ ជំណាមក ហើយ ៗ ព្រះសុមេធាចារ្យបាននិមន្តចេញពីស្រុកមនមកសំដែងព្រះធម៌វិន័យប្រកាសផ្សាយ ព្រះពុទ្ធសាសនាក្នុងប្រទេសថៃ ៗ គ្រានោះ សម្តេចព្រះបរមក្លៅ បានទតឃើញឥរិយាបថនឹងបានស្តាប់ធម៌ទេសនា អំពីផ្លូវវត្តប្រតិបត្តិហើយ ក៏កើតសទ្ធាជ្រះថ្លាទ្រង់ជឿជាក់ថា ព្រះមហាថេរអង្គនេះជាពូជព្រះអរិយៈមែន ទើបទ្រង់ទទួលគោរពប្រតិបត្តិសិក្សាវិន័យព្រះត្រៃបិដក ក្នុងសំណាក់នៃព្រះសុមេធាចារ្យជាប់រៀងមក ៗ

លុះដល់មកឆ្នាំចអដ្ឋស័ក ព. ស. ២៣៦៩ គ.ស. ១៨២៦ ម.ស. ១៧៤៨ ច.ស. ១១៨៨ សម្តេចព្រះចមក្លៅបានចូលប្រឡងប្រែព្រះត្រៃបិដក នៅព្រះទីនាំងអមរិន្ទវិនិច្ឆ័យ ជាមួយនឹងសម្តេចព្រះវនរតន៍ ជាប់,

ព្រះញាណវគ្គិត ស្មុ ១, ព្រះសមុទ្ទមុនី ឃាំ ៨, ព្រះអមរកវិវគ្គិត កើត គុនវេង ៣ ថៃស្រេចហើយ ជាប់ជាទីព្រះមហា ៤ ព្រះយោគ ស្មើគ្នាទាំង ៥ ព្រះអង្គ ខាងក្រោយមកបានប្រែប្រឡងបំពេញតមកទៀត ជាប់បានជាទីព្រះមហា ៨-៩ ប្រយោគគ្រប់ព្រះអង្គ ព្រះមហាថេរទាំង៥ ព្រះអង្គ មានសម្តេចព្រះបមក្សាជាប្រធាន ខំតាំងព្យាយាមផ្ទៀងផ្ទាត់ពិនិត្យធម៌វិន័យ រិះរកសេចក្តីប្រតិបត្តិខុសត្រូវតាមគម្ពីរព្រះត្រៃបិដក ហើយបានសំដែងប្រាប់ពួកពុទ្ធបរិស័ទឲ្យលះបង់ផ្លូវប្រតិបត្តិខុសចោលចេញ ហើយដឹកនាំឲ្យប្រតិបត្តិត្រឹមត្រូវតាមធម៌វិន័យវិញ ។ សម័យនោះ ពួកពុទ្ធបរិស័ទបានស្តាប់ធម៌ទេសនា នៃព្រះមហាថេរទាំងនោះហើយ ក៏យល់ធម៌វិន័យ ស្គាល់ផ្លូវប្រតិបត្តិខុសត្រូវទើបកើតសទ្ធាជ្រះថ្លា នាំគ្នាប្រគល់កាយថ្វាយខ្លួនជាសិស្ស សូមរៀនសូត្រធម៌វិន័យហើយចូលបួសតាមជាច្រើននាក់ ។

លុះដល់ឆ្នាំឆ្លូវឯកស័ក ព.ស. ២៣៧២ គ.ស. ១៨២៩ ម.ស. ១៧៥១ ច.ស. ១១៩១ សម្តេចព្រះបមាក្សាទ្រង់ស្តេចយាងចេញពីវត្តមហាធាតុទៅគង់នៅវត្តរាជាធិវាសវិញ ដើម្បីនឹងប្រកាសផ្សាយព្រះពុទ្ធសាសនាឲ្យបានរុងរឿងរីកតែខ្លាំងឡើង ។ សម័យនោះ ព្រះអង្គមានព្រះទ័យ

រង្គៀសសង្ស័យនឹងសីមាវត្តជាធិក់សន៍នោះក្រែងមិនត្រឹមត្រូវតាមពុទ្ធប្ប-ញត្តិ ទើបទ្រង់ប្រើមនុស្សឲ្យគាស់ជុំនិមិត្តសីមាឡើងយកមកទតពិនិត្យមើល ទ្រង់ជ្រាបថានិមិត្តសីមានោះខុសពីពុទ្ធប្បញ្ញត្តិ ភិក្ខុសង្ឃនឹងធ្វើសង្ឃកម្មទាំងពួងមិនឡើងជាកម្មឡើយ ហេតុនេះ ទើបទ្រង់ចាត់មនុស្សឲ្យដើរស្វែងរកព្រះសង្ឃដ៏បរិសុទ្ធ ដែលបានឧបសម្បទក្នុងបុរាណសីមាដែលពិតប្រាកដជាព្រះអរហន្តចងទុកមកមែន ។

បំណេរកាលជាខាងក្រោយមក បានព្រះសង្ឃលង្កាវង្សចំនួន ២៧ អង្គនិមន្តពីលង្កាទ្វីប មកគង់នៅវត្តជាធិកសន៍ក្នុងប្រទេសថៃ ។ វេលានោះ សម្តេចព្រះបមក្លៅទ្រង់សាកសួរអំពីវិធីឧបសម្បទ ដោយញត្តិចតុត្ថកម្មវាចា សួរអំពីសម្បត្តិ ៤ វិបត្តិ ៤ ប្រការក្នុងឧបសម្បទកម្ម ។ ព្រះសង្ឃលង្កាវង្សទាំងនោះ ឆ្លើយទូលត្រឹមត្រូវតាមព្រះវិន័យបញ្ញត្តិដែលព្រះអង្គចេះចាំមក ទើបទ្រង់ជ្រាបច្បាស់ថា ព្រះសង្ឃលង្កាវង្សទាំងនោះបានឧបសម្បទដោយញត្តិចតុត្ថកម្មវាចាក្នុងថូបារាមវិហារ មានសីមាដែលព្រះមហាមហិន្ទត្ថេរបានចងទុកមក ។ ទើបសម្តេចព្រះបមក្លៅមានសទ្ធាជ្រះថ្លានិមន្តព្រះសង្ឃលង្កាវង្សទាំង ២៧ អង្គនោះជាគណការកសង្ឃទ្រង់ឧបសម្បទម្តងទៀតជាគំរប់ ២ ដង ។

នៅទីព្រះឧបោសថផែសីមាទឹក នាមុខវត្តពជាធិវាសន៍នោះ រួចស្រេចហើយទ្រង់បេះតែខំផ្សាយពង្រីកគណៈធម្មយុត្តិកនិកាយនេះឲ្យរីកតែចំរើនច្រើនឡើងក្នុងប្រទេសថៃតរៀងមក ។

លុះដល់ឆ្នាំវកអដ្ឋស័ក ព.ស. ២៣៧៩ គ.ស. ១៨៣៦ ម.ស. ១៧៥៨ ច.ស. ១១៩៨ សម្តេចក្រុមព្រះបវរទ្រង់កសាងវត្តបវរនិវេស និងវត្តបរមនិវាស លុះសាងស្រេចហើយ ទើបសម្តេចព្រះចមក្លៅទ្រង់ឲ្យប្រជុំព្រះសង្ឃបរិស័ទចំនួន ៥០ អង្គ ធ្វើសីមានៅវត្តទាំងពីរជាសីមាទឹកទុកជាទីបព្វជ្ជាឧបសម្បទ និងធ្វើឧបោសថសង្ឃកម្មទាំងពួងស្រេចហើយ ទ្រង់គង់នៅវត្តបវរនិវេស ចាត់ព្រះញាណរក្ខិត (សុខ) ឲ្យទៅគង់នៅវត្តបរមនិវាសវិញជាដំណាងព្រះអង្គ ។

## អំពីការជាស្នាព្រះហស្ត

គ្រានោះសម្តេចព្រះចមក្លៅទ្រង់បានរៀបរៀងវិធីកឋិន និងវិធីសង្ឃកម្មផ្សេង ៗ ឲ្យមានរបៀបរៀបរយឡើង ទុកជាក្បួនច្បាប់ត្រឹមត្រូវតាមព្រះវិន័យពុទ្ធបញ្ញត្តិនិងពុទ្ធានុញ្ញាត ដែលមានក្នុងគម្ពីរព្រះត្រៃបិដក ដើម្បីទុកឲ្យពួកពុទ្ធបរិស័ទធម្មយុត្តិកនិកាយរៀនសូត្រឲ្យបានចេះដឹងហើយ

ប្រតិបត្តិតាមជាប់រៀងរហូតមកដល់សព្វថ្ងៃនេះ ។

តាំងពីគ្រានោះមក គណៈធម្មយុត្តចេះតែរីកសាយភាយចេញទៅពេញទាំងប្រទេសថៃ កើតមានវត្តគណៈធម្មយុត្តកាន់តែច្រើនឡើង ទាំងក្នុងក្រុងនិងខេត្តក្រៅ ។ ខាងព្រះរាជអាណាចក្រ ក៏ទទួលស្គាល់ គោរពរាប់អានលើកដំកើងគណៈធម្មយុត្ត ទុកជាផ្លូវការ រាប់ថាជាពួកអ្នកប្រព្រឹត្តត្រឹមត្រូវតាមព្រះធម៌វិន័យក្នុងព្រះពុទ្ធសាសនាពិតប្រាកដ ។

## អំពីទ្រង់សោយរាជ្យនឹងទិវង្គត

លុះដល់ខាងក្រោយមក ព្រះបាទសម្តេចព្រះណាំងក្លៅរជ្ជកាលទី ៣ ទ្រង់ទិវង្គតទៅនៅថ្ងៃ ៤ ១ ៥ ឆ្នាំចទោស័ក ព.ស. ២៣៩៣ គ.ស. ១៨៥០ ម.ស. ១៧៧២ ច.ស. ១២១២ ។

ព្រះបាទសម្តេចព្រះចមក្លៅ ទ្រង់ព្រះផ្នួសបាន ២៧ វស្សា ព្រះជន្ម ៤៧ ឆ្នាំ ទ្រង់លាព្រះផ្នួសទទួលរាជសម្បត្តិមកនៅថ្ងៃខែ ឆ្នាំ ដូចខាងលើនេះ ។ ព្រះអង្គសោយរាជ្យសម្បត្តិបាន ១៨ ឆ្នាំ ។ ក្នុងព្រះជន្មគំរប់ ៦៥ ឆ្នាំ ទ្រង់ទិវង្គតនៅថ្ងៃមហាបវារណាចេញវស្សា គឺថ្ងៃ ៥ ១៥ ១១ ឆ្នាំ រោងសំរឹទ្ធិស័ក ព.ស. ២៤១១ គ ស. ១៨៦៨ ម.ស. ១៧៩០ ច.ស. ១២៣០ ។

ព្រះរាជប្រវត្តិនៃព្រះបាទសម្តេចព្រះបរមរាជា

សន្ធៃបតែប៉ុណ្ណោះ ។

## សេចក្តីបញ្ជាក់របស់អ្នករៀបរៀង

ព្រះរាជប្រវត្តិនៃព្រះបាទសម្តេចព្រះបរមរាជានេះ ខ្ញុំបានស្រង់ប្រែចេញទីឯផ្សេងៗតាមច្បាប់ទាំងនេះគឺ ៖

ទី ១– ច្បាប់ព្រះរាជពង្សាវតារ ប្រទេសថៃរដ្ឋកាលទី ២ ក្រុងរតនកោសិន្ទ្រ ។

២– ច្បាប់ប្រវត្តិសាស្ត្រសាកល របស់ហ្លួងវិចិត្រវាទការអក្សរពុម្ពថៃ ។

៣– ច្បាប់បុរសអាជាខេមរ របស់សាសនសោភណអក្សរពុម្ពថៃ បោះពុម្ពគ.ស.២៤៩២ ។

៤– ច្បាប់ធម្មយុត្តនិកាយមហានិកាយអក្សរពុម្ពថៃ ។

៥– ច្បាប់ថេរប្បញ្ញត្តិអក្សរពុម្ពថៃ ។

៦– ច្បាប់វិន័យវណ្ណនាអក្សរពុម្ពខ្មែរ ។

ធម្មយុត្តិកប្រវត្តិកង់ប្រទេសថៃ

សន្ធៃបតែប៉ុណ្ណោះ

# ធម្មយុត្តិកប្រវត្តិសង្ខេប

## ក្នុងប្រទេសកម្ពុជា

គណៈធម្មយុត្តដែលបានឧប្បត្តិឡើង ជាដំបូងក្នុងប្រទេសថៃតាំងពី ព.ស. ២៣៧២ ហើយបានផ្សាយចេញពីប្រទេសថៃចូលមកប្រតិស្ឋានក្នុងប្រទេសកម្ពុជា តាំងពី ព.ស. ២៣៩៧ គ.ស ១៨៥៤ ម.ស ១៧៧៦ ច.ស. ១២១៦ ។

សម្តេចព្រះសុគន្ធាសំយកជាគណាធិបតី បញ្ញាសីលោ (ប៉ាន) ព្រះអង្គបានចាប់ផ្តើមស្ថាបនាធម្មយុត្តិកវង្ស ក្នុងប្រទេសកម្ពុជាមុនគេបំផុត ដូចមានសេចក្តីរៀបរាប់ក្នុងប្រវត្តិដោយសង្ខេបតទៅនេះ ។

## ប្រវត្តិសង្ខេប [១]

### នៃសម្តេចព្រះសុគន្ធាសំយកជាគណាធិបតី បញ្ញាសីលោ (ប៉ាន)

សម្តេចទ្រង់សម្ភពនៅថ្ងៃ ៥ ៗ ១ ១២ ឆ្នាំចអដ្ឋស័ក ព.ស. ២៣៦៩ គ.ស. ១៨២៦ ម.ស. ១៧៤៨ ច.ស. ១១៨៨ នៅភូមិព្រែកព្រះស្តេច ខេត្របាត់ដំបង ។ ឯស្រុកកំណើតមាតាបិតានៃសម្តេច នៅភូមិស្ពាន

១– ស្រង់ចាកច្បាប់វិន័យវណ្ណនា កាត់យកតែគោល ៗ ។ ប៉ុន្តែបានកែតម្រូវសករាជខ្លះ ព្រោះច្បាប់នេះមានកាន់ច្រឡំសករាជ ។

ស្រុកស្ទោង ខែត្រកំពង់ធំ ។ កាលដែលមាតាបិតាឃ្លាតទៅនៅខែត្របាត់ដំបងនោះ មកពីហេតុកើតចលាចលនៃទឹកញ៉ាគេជា (នៃឧ) ។ ឯមាតាបិតានៃសម្ដេចមាននាមដូចម្ដេចពុំបានដឹងប្រាកដ ។

កាលសម្ដេចព្រះជន្ម ១៦ ឆ្នាំ បានបព្វជ្ជាជាសាមណេរនៅវត្តពោធិ៍កុង ឃុំសង្កែ ខែត្របាត់ដំបង ហើយចូលទៅនៅក្រុងទេពប្រទេសថៃ គង់នៅវត្តសះកេតគណៈមហានិកាយ ទ្រង់បានចាប់ផ្ដើមសិក្សាព្រះត្រៃបិដកតាំងពីព្រះជន្ម ១៣ ឆ្នាំ រហូតដល់ព្រះជន្ម ២១ ឆ្នាំ បានឧបសម្បទជាភិក្ខុគណៈមហានិកាយ គង់នៅវត្តសះកេតនោះបាន ៤ វស្សា ។

វេលានោះក្រុមហ្លួនក្សត្រខ្មែរជាញោមឧបដ្ឋាក នាំសម្ដេចទៅថ្វាយសម្ដេចព្រះបរមគ្រូ ឲ្យទៅសិក្សាសិក្ខាវិន័យ ក្នុងសំណាក់ទៅឃុនព្រះញាណរក្ខិត (សុខ) ទៅអធិការវត្តបវរនិវេសគណៈធម្មយុត្ត ។

លុះកាលកន្ទង់មកក្នុងថ្ងៃ ៗ ៨ ឆ្នាំរកា ឯកស័ក ព.ស. ២៣៩២ គ.ស. ១៨៤៩ ម.ស. ១៧៧១ ច.ស ១២១១ សម្ដេចព្រះជន្ម ២៤ ឆ្នាំបានចូលបព្វជ្ជាឧបសម្បទ ជាភិក្ខុក្នុងគណៈធម្មយុត្ត ។ សម្ដេចព្រះបរមគ្រូជាព្រះឧបជ្ឈាយ៍ ចៅឃុនព្រះញាណរក្ខិត (សុខ) ជាកម្មវាចា ព្រះអមរាភិរក្ខិត (កើត) ជាអនុសាវនាចារ្យ បាននាមគាថាថា «បញ្ញាសីលោ» កាល

ទុបសម្ព័ទស្រេចហើយកគង់នៅវត្តបរមនិវាសន៍រៀងមក ។ លុះដល់ បេញវស្សាសម្តេចបានចូលប្រែប្រយោគ ក្នុងវត្តព្រះកែវហ្ងងនៅក្រុងទេព បាន ៤ ប្រយោគបានទទួលសមណសក្តិជាមហាទ្រង់គ្រឿង ។

ខាងក្រោយមក មានព្រះរាជសុភអក្សរនៃព្រះបាទសម្តេចព្រះហរិ-រក្សរាមាឥស្សរាធិបតី (ព្រះអង្គឌួង) ព្រះចៅប្រទេសកម្ពុជាឲ្យទៅសុំគណៈធម្មយុត្តអំពីប្រទេសថៃមកប្រតិស្ឋានក្នុងប្រទេសកម្ពុជា ។ គ្រានោះព្រះចមក្លៅថ្វាយគម្ពីរព្រះត្រៃបិដក ៨០ គម្ពីរ ហើយទ្រង់អារាធនាចៅឃុនព្រះអមរាភិរក្ខិត (គោ ត) និងព្រះសង្ឃ ៨ អង្គ ឧបាសក ៤ នាក់ឲ្យជូនព្រះមហា ប៉ាន មកគង់នៅប្រទេសកម្ពុជា ក្នុងឆ្នាំខាល ឆស័ក ព.ស. ២៣៩៧ គ.ស. ១៨៥៤ ម.ស. ១៧៧៦ ច.ស. ១២១៦ ។ ព្រះបាទសម្តេចព្រះអង្គឌួង ទ្រង់និមន្តព្រះមហា ប៉ាន ឲ្យគង់នៅវត្តសាលាគូ (វត្តអម្ពិលប៊ី) ក្រុងឧត្តុង្គមានជ័យ ។ ព្រះមហា ប៉ាន ក៏ចាប់ផ្តើមព្យាយាមផ្សាយធម្មវិន័យគណធម្មយុត្តឲ្យសាយភាយទូទៅក្នុងប្រទេសកម្ពុជា តាំងពីគ្រានោះមក ។

## អំពីសមណសក្តិនៃសម្តេច

ទី ១– ជាព្រះអរិយវង្ស ទីកជាគណៈ

២ ជាព្រះវិមលធម្ម ទីកជាគណៈ

៣- ជាព្រះមហាវិមលធម្ម "

៤- ជាសម្ដេចព្រះសុគន្ធសំយកជាគណាធិបតី សង្ឃនាយក

(មានព្រះរាជបញ្ញត្តិឲ្យទូលឆ្លើយដោយពាក្យរាជសព្ទទាំងអស់) ។

## អំពីក្រុងភ្នំពេញ និងវត្តបុទុមវតីវរារាម

ខាងក្រោយមកព្រះបាទសម្ដេចព្រះនរោត្តម ព្រះចៅប្រទេសកម្ពុជាទ្រង់ស្ដេចយាងចេញពីក្រុងឧត្តុង្គមានជ័យមកកសាងក្រុងថ្មីនៅភ្នំពេញវិញ ។ វេលានោះទ្រង់ត្រាស់ឲ្យរៀបចំផ្លាស់ផ្ដូរវត្តឧបគាយ៉ង ជាវត្តចាស់បុរាណរបស់គណៈមហានិកាយរួចផ្លាស់ឈ្មោះវត្តឲ្យហៅថា "វត្តបទុមវតីរាជវរារាម" ជាវត្តរបស់គណៈធម្មយុត្តិវិញ ទីដីវត្តនេះមានទីទំង ៤សិនបណ្ដោយ ៥សិន ហើយទ្រង់និមន្តសម្ដេចព្រះសុគន្ធាសំយកជាគណាធិបតី ចាំង ពីវត្តសាលាគួរឲ្យមកគង់នៅវត្តបទុមវតី ក្រុងភ្នំពេញវិញ នៅឆ្នាំឆ្លូវសប្តស័ក ព.ស. ២៤០៨ គ.ស. ១៨៦៥ ម.ស. ១៧៨៧ ច.ស. ១២២៧ ។

---

(១) មានសេចក្ដីពិស្ដារក្នុងច្បាប់ព្រះរាជពង្សាវតារក្រុងកម្ពុជា ក្នុងរជ្ជកាលនៃព្រះបាទសម្ដេចព្រះនរោត្តមបរមទេវាវតារ ។

# អំពីកិច្ចការជាស្នាព្រះហស្តនៃសម្តេច

សម្តេចបានស្តេចទៅប្រទេសថៃមួយលើកទៀត ។ បានបង្កើតវត្ត គណៈធម្មយុត្ត ជាច្រើនទុកក្នុងប្រទេសកម្ពុជា បានរៀបរៀងក្បួនច្បាប់ ធម៌វិន័យ មានវិន័យវណ្ណនា បុព្វសិក្ខា វិធីថ្វាយបង្គំព្រះវត្តព្រឹក-ល្ងាច, វិធីប្រតិបត្តិផ្នែកខាងឧបាសក-ឧបាសិកា មានការសមាទានសីល-ស្តាប់ធម៌ទេសនាជាដើម តាមថ្ងៃកាល ផ្សាយទូទៅគ្រប់វត្តខាងគណធម្មយុត្តិកនិកាយ ។ សម្តេចបានប្រាប់រឿងព្រេងខ្មែរផ្សេង ៗ ឲ្យលោក « អៃម៉ូ ឌីញ៉េ » យកទៅបោះពុម្ពជាក្បួនទុកនៅប្រទេសបារាំង, បានសូមព្រះរាជានុញ្ញាតឲ្យព្រះស្រីគះជន្ធធម្ម ចាប នឹងព្រះសង្ឃ ៤ អង្គ នាំយកគ្រឿងសក្ការបូជាទៅឯលង្កាទ្វីប ដើម្បីផ្ទៀងផ្ទាត់ធម្មវិន័យព្រះពុទ្ធសាសនា ។

វេលាជាបន្ទាប់នោះ ព្រះសុភូតិមហាថេរ រាមញ្ញវង្ស បានចាត់ឲ្យព្រះ~~មហាណា~~គ្រូ នាំយកគ្រឿងសក្ការបូជាថ្វាយមកវិញ គឺព្រះបរមសារីរិកធាតុ ១ ព្រះអង្គ, ព្រះអរហន្តធាតុ ១ ព្រះអង្គ, នឹងកូនព្រះមហាពោធិព្រឹក្ស ១ ព្រះអង្គ ។

សម្តេចបានចាត់ឲ្យដាំកូនព្រះមហាពោធិព្រឹក្សនោះ នៅមុខព្រះ

វិហារវត្តបទុមវតី ពីថ្ងៃ ៣ ៗ ១០ ៣ ឆ្នាំកុរនព្វស័ក ព.ស. ២៤៣០ គ.ស. ១៨៨៧, ម.ស. ១៨០៩ ច.ស. ១២៤៩ ទុកជាគោលចារិកនៃព្រះពុទ្ធសាសនាតរៀងទៅ ។

ក្រោយពីការដាំព្រះមហាពោធិព្រឹក្ស សម្តេចក៏ប្រារព្ធសាងព្រះចេតិយ ១ អង្គធំ ដើម្បីប្រតិស្ឋានព្រះបរមសារីរិកធាតុ នឹងព្រះអរហន្តធាតុ ប៉ុន្តែ ពុំទាន់បានសាងរួចនៅឡើយ ស្រាប់តែមានព្រះរោគប្រឈួនជាទម្ងន់ គ្រាតែផុតក្តីសង្ឃឹម, ដែលនាំឲ្យពុទ្ធបរិស័ទក្រោមទីរាបទាំងអស់ មានសេចក្តីរំភើបញាប់ញ័រឥតឧបមា ។

## អំពីទិវង្គតនៃសម្តេច

សម្តេចប្រឈួនចុកសៀតព្រះឧទរ ទិវង្គត នៅថ្ងៃ ៧ ៗ ៤ ៣ ឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៣៦ គ.ស. ១៨៩៣ ម.ស. ១៨១៥ ច.ស. ១២៥៥ ក្នុងព្រះជន្ម ៦៨ ឆ្នាំ វស្សាគំរប់ ៤៨ ។

វិធីបុណ្យមេរុបូជាព្រះសពនៅថ្ងៃ ៤ ៗ ១០ ៦ ឆ្នាំកុរឯកស័ក ព.ស. ២៤៤២ គ.ស. ១៨៩៩ ម.ស. ១៨២១ ច.ស. ១២៦១ នៅវាលមេរុខាងជើងព្រះបរមរាជវាំងចតុម្មុខក្រុងភ្នំពេញ ក្នុងឱកាសពិធីបុណ្យមេរុថ្វាយព្រះ-

---

១– ស្រង់ចេញពីច្បាប់ព្រះរាជពង្សាវតារក្រុងកម្ពុជាធិបតីភាគទី ៧ ទំព័រ ៩៧៥ ... ។

ភ្លើង ព្រះបរមសពនៃសម្តេចព្រះវររាជជននីនាថ (ម៉ែន) ជាអគ្គមហេសី ព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតីព្រះអង្គឌួង ។

ធ្វើបុណ្យបញ្ចុះព្រះអដ្ឋិនៃសម្តេច នៅចេតិយអង្គធំក្នុងវត្តបទុមវតី នៅថ្ងៃ ៤ ១ ។ ៦ ឆ្នាំរកាឯកស័ក ព.ស. ២៤៥២ ត្រូវនឹងថ្ងៃ ៨ ខែឧសភា គ.ស ១៩០៩ ម.ស. ១៨៣១ ច.ស. ១២៧១ ។ កាលពី គ.ស. ១៩៥៣ អ្នកឧកញ៉ាមហាមន្ត្រី ញ៉ុក ធា ឆ្ងរ ជាមេគំនិតបានឃោសនាពួកពុទ្ធបរិស័ទរួបរួមបច្ច័យជួលជាងប្រទេសបារាំង ឲ្យសិតព្រះរូបនៃសម្តេចដោយលង្ហិនកំពស់ ៧០ សង់ទីម៉ែត្រ ថ្លៃជាង ២០ ម៉ឺនរៀល ចម្លងតាមព្រះរូបដែលថតគង់នៅក្មេង ដើម្បីទុកជាអនុស្សរណ៍ជាគោលបារិកកត្តុតាំងទៅអនាគតកុំឲ្យសាបសូន្យ ទុកគ្រាន់ជាទីរឭកនឹកព្រះគុណដែលទ្រង់បាននាំគណៈធម្មយុត្តិកនិកាយមកតាំងនៅក្នុងកម្ពុជរដ្ឋយើងនេះ ។

## ព្រឹត្តិការណ៍សំខាន់

សម្តេចព្រះសុគន្ធាយកជាគណាធិបតីនិមន្តមកពីប្រទេសថៃ កាលពីថ្ងៃអាទិត្យ ១០ កើតខែមាឃ ឆ្នាំខាលឆស័ក ព.ស. ២៣៩៨/គ.ស. ១៨៥៤

សម្តេចចូលព្រះទិវង្គត នៅថ្ងៃសៅរ៍ ៤ កេចខែមាឃ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស.២៤៣៦, គ.ស. ១៨៩៣ ក្នុងព្រះជន្មាយុ ៦៨ ឆ្នាំ វស្សា ៤៨ ។

ចប់

# ប្រវត្តិសង្ខេប

## នៃសម្តេចព្រះមង្គលទេពាចារ្យ ព្រះនាម «អៀម»(១)

សម្តេចសម្ភពនៅថ្ងៃ ១ ៗ ៤ ឆ្នាំរកាឯកស័ក ព.ស. ២៣៩២ គ.ស. ១៨៤៩ ម.ស. ១៧៧១ ច.ស. ១២១១ នៅឃុំព្រៃពួច ស្រុកសំរោងទង ខេត្រកំពង់ស្ពឺ មាតានាម អ៊ុក បិតានាម «ម៉ឹង» ។

សម្តេចព្រះជន្ម ៨ ឆ្នាំ បានរៀនអក្សរសាស្ត្រខ្មែរក្នុងសំណាក់លោកគ្រូសូត្រ «ទេព» នៅវត្តព្រៃពួច គណៈមហានិកាយ ដល់ព្រះជន្ម ១៣ ឆ្នាំបព្វជ្ជាជាសាមណេរនៅវត្តព្រៃពួចនោះបាន ២ វស្សាចាកសិក្ខាបទមកវិញ ទើបលោកឧកញ៉ាសុភាធិបតី «មាំ» ត្រូវជាឪពុកធំនៃសម្តេចបង្កើត បាននាំទៅថ្វាយសម្តេចព្រះសុគន្ធាសំយកជាគណាធិបតី ប៉ាន គង់នៅវត្តសាលាគួរ ក្រុងឧត្តុង្គមានជ័យ ។ ដល់ព្រះជន្ម ២១ ឆ្នាំ បានឧបសម្បទជាភិក្ខុ សម្តេចព្រះសុគន្ធាធិបតី ប៉ាន ជាព្រះឧបជ្ឈាយ៍ ព្រះពោធិវង្ស ចាន់ ទៅអធិការវត្តស្វាយពពែជាកម្មវាចា ព្រះព្រហ្មមុនី ទេព ជាអនុសាវនាចារ្យ បាននាមឆាយាថា (គន្ធគូ) ក្នុងសីមាវត្តបទុមវតីក្រុងភ្នំពេញ នៅឆ្នាំមមីទោស័ក ព.ស. ២៤១៣ គ.ស. ១៨៧០ ម.ស. ១៧៩២ ច.ស. ១២៣២ ។

---

១- ស្រង់តែគោល ៗ ពីច្បាប់ប័ក្ខគណនាវិធី នឹងប័ក្ខសម្រេចរបស់ពុទ្ធសាសនបណ្ឌិត្យ លេខ ម. ២៦ ទំព័រ ៣-៦ ។ ប៉ុន្តែមានកែប្រែពាក្យខ្លះ ព្រោះច្បាប់ដើមមានភាន់ច្រឡំខ្លះ។

# អំពីសមណសក្តិនៃសម្តេច

ទី១– ព្រះសមុហ៍ព្រហ្មសត្ថា ទីហ៉ានា

២– ព្រះបាឡាត់ព្រហ្មវិជ្ជា ទីហ៉ានា

៣– ព្រះគ្រូបញ្ញាវិន័យ „

៤– ព្រះកម្ពុគោត្តម ទីរាជាគណៈ

៥- ព្រះមហាព្រហ្មមុនី „

៦– ជាចៅអធិការវត្តបទុមវតី ស្តីទីសង្ឃនាយក

៧– សម្តេចព្រះវនរតន៍ ទីសង្ឃនាយក

៨– សម្តេចព្រះមង្គលទេពាចារ្យ ទីសង្ឃនាយក

ក្នុងព្រះជន្មគំរប់ ៥៩ ឆ្នាំ នៅឆ្នាំវកសំរិទ្ធិស័ក ព.ស. ២៤៥១ គ.ស. ១៩០៨ ម.ស. ១៨៣០ ច.ស. ១២៧០ ។

# អំពីគ្រឿងឥស្សរិយយសនៃសម្តេច

១– ស៊ុវ៉ាលីយេដឺឡាឡេស្យុងដូណេរ

នៅថ្ងៃ ២១ ខែ សីហា គ.ស. ១៩១១ ។

# អំពីកិច្ចការជាស្នាព្រះហស្តនៃសម្តេច

សម្តេចបានចាប់ផ្តើមផ្សុលវិហារចាស់នៅវត្តបទុមវតី ទើបបានក-

សាងកេងដួង ១ ក្នុងវត្តបទុមវតី ។ បានសាងព្រះពុទ្ធរូបស្ពាន់អង្គធំ ១ ព្រះអង្គ ដំកល់នៅវត្តព្រៃព្ធួច នឹងសាងសាលា ១ ខ្នង បានជាវគម្ពីរព្រះត្រៃបិដកស៊ីករតែខ្វះ ។ បានចាត់ការកសាងព្រះចេតិយអង្គធំ ១ នៅវត្តបទុម-វតីបន្តពីសម្តេចព្រះសុគន្ធមក លុះសាងរួចស្រេចហើយប្រតិស្ឋានព្រះបរមសារីរិកធាតុ ១ ព្រះអង្គ ព្រះអរហន្តធាតុ ១ ព្រះអង្គនឹងព្រះអដ្ឋិធាតុនៃស-ម្តេចព្រះសុគន្ធាធិបតី ចា៉ឈ នៅថ្ងៃ ៤ ៗ១ ៦ ឆ្នាំរោងឯកស័ក ព.ស. ២៤៥២ ត្រូវនឹងថ្ងៃ ៨ ខែ ឧសភា គ.ស. ១៩០៩ ម.ស. ១៨៣១ ច.ស. ១២៧១ ។

## អំពីអនិច្ចធម្មនៃសម្តេច

សម្តេចបានទទួលនាទីព្រះសង្ឃនាយកចំនួន ១៤ ឆ្នាំ ប្រឈួនចុកសៀតព្រះឧទរ អនិច្ចធម្មនៅថ្ងៃ ៥ ៗ១ ១ ឆ្នាំចចត្វាស័ក ម.ស. ១៨៤៤ ព.ស. ២៤៦៥ គ.ស. ១៩២២ ច.ស. ១២៨៤ ពេលម៉ោង ៩ ព្រឹកក្នុងព្រះជន្មគំរប់ ៧៣ ឆ្នាំ វស្សាបាន ៥២ ។

ដំកល់ព្រះសពទុកចំនួន ៦ ខែ ធ្វើបុណ្យមេរុបូជាព្រះសពនៅមុខវត្តបទុមវតី ក្រុងភ្នំពេញ ក្នុងរជ្ជកាលនៃព្រះបាទសម្តេចព្រះស៊ីសុវត្ថិ (ព្រះបរមកជានុកោដ្ឋ) ។

ដំកល់ព្រះអដ្ឋិធាតុនៃសម្តេចតមកចំនួន ២១ ឆ្នាំគត់ ហើយបានបញ្ចុះ-

ក្នុងព្រះចេតិយអង្គធំ ថ្ងៃ៥ ១៣ ៗ ៤ ឆ្នាំមមី ចត្វាស័ក ព.ស. ២៤៨៥ ត្រូវនឹង ថ្ងៃ ១៨ ខែ មីនា គ.ស. ១៩៤២ ម.ស. ១៨៦៤ ច.ស. ១៣០៤ ក្នុងឱកាសពិធីបុណ្យមេរុបូជាព្រះសពសម្តេចមង្គលទេព្វាចារ្យ ស៊ុក នឹងពិធីបុណ្យសម្ពោធឆ្លងព្រះវិហារថ្មី នៅវត្តបទុមវតីរាជវរារាម ក្រុងភ្នំពេញ ៗ

ចប់

# ប្រវត្តិសង្ខេប

## នៃសម្តេចព្រះមង្គលទេព្វាចារ្យព្រះនាម « ស៊ុំ គា »(១)

សម្តេចសម្ភពនៅថ្ងៃ ៥ ៗ ៣ ឆ្នាំរកាត្រីស័ក ព.ស. ២៤០៤ គ.ស. ១៨៦១ ម.ស. ១៧៨៣ ច.ស. ១២២៣ ក្នុងស្រុកនគររាជប្រទេសថៃ បិតានាម អៀម មាតានាម ម៉ៅ ៗ លុះដល់ក្រោយមកមាតាបិតាចុះមកនៅភូមិរុន ស្រុកក្រឡាញ់ ខែត្របាត់ដំបងវិញ កាលខែត្រនេះនៅក្នុងអំណាចប្រទេសថៃ ៗ

សម្តេចកាលពីកុមារបានសិក្សាអក្សរសាស្ត្រខ្មែរ នៅវត្តសំពៅលូន ភូមិរុន ស្រុកក្រឡាញ់ លុះដល់ព្រះជន្ម ២១ ឆ្នាំបានឧបសម្បទជាភិក្ខុគណៈមហានិកាយនៅវត្តសំពៅលូននោះ ក្នុងឆ្នាំ ម្សាញ់ត្រីស័ក ព.ស.២៤២៤ គ.ស. ១៨៨១ ម.ស. ១៨០៣ ច.ស. ១២៤៣ ហើយគង់នៅវត្តសំពៅលូននោះបាន ៤ វស្សា សិក្សាអក្សរសាស្ត្រថៃចេះស្ទាត់ បានចូលមកសុំនៅក្នុងវត្តបទុមវតីក្រុងភ្នំពេញតាំងតែជាមហានិកាយ នៅគង់សំណាក់ព្រះមហាព្រហ្មមុនី គោត កាលដែលលោកនៅជាមហា៤ប្រយោគ បានសិក្សាធម្មវិន័យជ្រាបផ្លូវវត្តប្រតិបត្តិត្រឹមត្រូវហើយ ក៏និមន្តសម្តេចព្រះ

---

១–ស្រង់យកតែគោល ៗ អំពីច្បាប់ប័ត្តគណៈនាវីធីនឹងប័ត្តសម្រេចរបស់ពុទ្ធសាសនបណ្ឌិត្យ លេខ ម. ២៦ ទំព័រ ៧. ១១ ។

សុគន្ធាសំយកជាគណាធិបតី ចាំង ជាព្រះឧបជ្ឈាយ៍ ព្រះមហាបទុមខេត ជាគម្ពាចារ្យបាននាមឆាយាថា «បញ្ញាធីរោ» ក្នុងសីមាវត្តបទុមវតីរាជវរារាម ក្រុងភ្នំពេញ ក្នុងព្រះជន្ម ២៨ នៅឆ្នាំជូតសំរិទ្ធិស័ក ព.ស. ២៤៣១ គ.ស: ១៨៨៨ ម.ស. ១៨៥០ ។

## អំពីសមណសក្តិនៃសម្តេច

ទី ១– ព្រះបាឡាត់ញាណរក្ខិត ទីឋានា

២– ព្រះធម្មបញ្ញាញាណ ទីរាជាគណ:

៣– ព្រះអរិយមុនី ”

៤– ព្រះមហាព្រហ្មមុនី ស្តីទីសង្ឃនាយក

៥– ព្រះមង្គលទេពាចារ្យ ”

៦– សម្តេចព្រះមង្គលទេពាចារ្យគណាធិបតីសង្ឃនាយក

## អំពីគ្រឿងឥស្សរិយយសនៃសម្តេច

១– ស្ហ៊ីវ៉ាលីយេដឺឡាឡេស្យុងដូណើរ ក្រុងបារាំងសែស

២– អូហ្វីស្យេរ –ដ– –ដ–

៣– គ្រង់អូហ្វីស្យេរ (វរសេនា) ក្រុងកម្ពុជា ។

# អំពីកិច្ចការជាស្នាព្រះហស្តនៃសម្តេច

សម្តេចបានកសាងសាលាបាលីរង ១ ខ្នង និងសាលាបំពេញវិជ្ជា ១ ខ្នង ក្នុងវត្តបទុមវតី ។ សម្តេចបានចាប់ផ្តើមគំនិតរុះរើវិហារចាស់ក្នុងវត្តបទុមវតីចេញ ហើយកសាងជាវិហារថ្មីឡើងវិញ ក្នុងឆ្នាំឆ្លូវនពស័ក ព.ស. ២៤៨០ គ.ស. ១៩៣៧ ម.ស. ១៨៥៩ ច.ស. ១២៩៩ ក្នុងរជ្ជកាលនៃព្រះបាទសម្តេចព្រះស៊ីសុវត្ថិ - មុនីវង្ស (ព្រះបរមខត្តិយកោដ្ឋ) ។ សម្តេចបានកសាងវត្តគណៈធម្មយុត្តិ ១ ឱ្យឈ្មោះថា «វត្តទួននាវិនាកម» នៅឃុំ . . . . ស្រុកទឹកដោរ ខេត្តបាត់ដំបង ។

## អំពីអនិច្ចធម្មនៃសម្តេច

សម្តេចបានទទួលនាទីជាសង្ឃនាយកចំនួន ២២ ឆ្នាំ អនិច្ចធម្មនៅថ្ងៃ ៥ ៗ១ ៦ ឆ្នាំមមីចត្វាស័ក ព.ស. ២៤៨៥ ត្រូវនឹងថ្ងៃ ៣០ ខែមេសា គ.ស. ១៩៤២ ម.ស. ១៨៦៤ ច.ស. ១៣០៤ វេលាម៉ោង ១១ និង ១៥ នាទី អគ្រាត្រ ដោយជរាពាធ ក្នុងព្រះជន្មគំរប់ ៨២ ឆ្នាំ ។ សម្តេចបួសក្នុងគណៈមហានិកាយបាន ៧ វស្សា ។

ដំកល់ព្រះសពទុកចំនួន ១១ ខែគត់ ទើបបានធ្វើបុណ្យមេរុបូជាព្រះសព នៅថ្ងៃ ៥ ១៣ៗ ៤ ឆ្នាំមមីចត្វាស័ក ព.ស. ២៤៨៥ ត្រូវនឹងថ្ងៃ

១៨ ខែមីនា គ.ស. ១៩៤២ ម.ស. ១៨៦៤ ច.ស. ១៣០៤ ហើយបញ្ចុះព្រះអដ្ឋិធាតុនៃសម្ដេចក្នុងព្រះចេតិយអង្គធំ ព្រមទាំងសម្ពោធឆ្លងព្រះវិហារថ្មី វត្តបទុមវតី នៅថ្ងៃខែខាងលើនេះ ក្នុងរជ្ជកាលនៃព្រះបាទសម្ដេចព្រះនរោត្តម-សីហនុវរ្ម័ន ម្ចាស់ផែនដីប្រទេសកម្ពុជា ។

ចប់

# ប្រវត្តិសង្ខេប

## នៃសម្តេចព្រះសុធម្មាធិបតីព្រះនាម «អ៊ុង-ស្រី»(១)

---

សម្តេចសម្ភពនៅថ្ងៃ៥ ១៣ ៗ ១ ឆ្នាំមមីទោស័ក ព.ស. ២៤១៣ គ.ស. ១៨៧០ ម.ស. ១៧៩២ ច.ស. ១២៣២ បិតានាម អ៊ុង មាតាឈៃ ស្រុកកំណើតនៅឃុំគោកទ្រព្យ ស្រុកកណ្តាលស្ទឹង ខែត្រកណ្តាល ។

សម្តេចព្រះជន្ម ២២ ឆ្នាំ បានឧបសម្បទជាភិក្ខុនៅថ្ងៃ ៥ ១៥ ៗ ៦ ឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៣៦ គ.ស. ១៨៩៣ ម.ស. ១៨១៥ ច.ស. ១២៥៥ សម្តេចព្រះសុគន្ធាធិបតី ទៀង ជាព្រះឧបជ្ឈាយ៍ សម្តេចព្រះមង្គលទេព្វាចារ្យ អៀម កាលនៅជាព្រះភន្តេគោត្តមជាកម្មវាចាចារ្យ បាននាមឆាយាថា «ពុទ្ធធាតោ» គង់សីមាវត្តបទុមវតី ឃុំលេខ៤ ក្រុងភ្នំពេញ ។ សម្តេចបានចេះដឹងព្រះត្រៃបិដក និងភាសាសៀមយ៉ាងច្បាស់លាស់ ។

## អំពីសមណសក្តិនៃសម្តេច

ទី ១ – ព្រះគ្រូវិន័យធម្ម ទំហានា នៅថ្ងៃ៥ ៨ ៗ ៦ ឆ្នាំ ចរោ-ស័ក ព.ស. ២៤៥៣ គ.ស. ១៩១០ ម.ស. ១៨៣២ ច.ស. ១២៧២

---

១- ស្រង់អំពីសំណុំរឿងតាំងព្រះសង្ឃនាយកគណៈធម្មយុត្តិឆ្នាំ ១៩៤៤ របស់ក្រសួងធម្មការ សេចក្តីពិស្តារមាននៅក្នុងសៀវភៅអនាថបិណ្ឌិកកោវិទសូត្រ ។

ក្នុងព្រះជន្មតំរប់ ៤០ ឆ្នាំ ។

ទី ២ – ព្រះធម្មុត្តម ទីកផាគណៈ នៅថ្ងៃ ១ ៗ ១២ ៦ ឆ្នាំឆ្លូវបញ្ចស័ក ព.ស. ២៤៥៦ ត្រូវនឹងថ្ងៃ ១ ខែមិថុនា គ.ស. ១៩១៣ ម.ស. - ១៨៣៥ ច.ស. ១២៧៥ ក្នុងព្រះជន្ម ៤៣ ឆ្នាំ ។

៣ – ព្រះធម្មវិរិយព្រឹទ្ធ ព.ស. ២៤៨៣ ។

៤ – សម្តេចព្រះសុធម្មាធិបតីទីសង្ឃនាយកនៅថ្ងៃ ១ ៗ ៦ ឆ្នាំវកឆស័ក ព.ស. ២៤៨៧ ត្រូវនឹងថ្ងៃ ២៣ ខែមេសា គ.ស. ១៩៤៤ ម.ស. ១៨៦៦ ច.ស. ១៣០៦ ក្នុងព្រះជន្មតំរប់ ៧៤ ឆ្នាំ ។

## អំពីកិច្ចការជាស្នាព្រះហស្តនៃសម្តេច

ក្នុងសម័យនៃសម្តេច បានចាត់ការបង្កើតជាវត្តជាច្រើនដូចជាកុដិ សាលា, កំពែងវត្តជាដើម ព្រមទាំងចាត់ដីបំពេញទីវត្ត ទឹងរៀបចំតុបតែងមុខវត្តឲ្យបានស្អាតបាតសមរម្យផង ដូចបានរៀបរាប់ក្នុងប្រវត្តិវត្តបទុមវតីខាងចុងស្រាប់ ។ល។ (១)

---

១– ប្រវត្តិនៃសម្តេចព្រះសុធម្មាធិបតីនេះ ពុំទាន់ចប់ទេ ត្រូវលោក-អ្នករៀបរៀងខាងក្រោយបន្តសេចក្តីក្នុង ។ល។ នេះតទៅទៀត ។

# និគមវិបត្តិ:

---

ធម្មយុត្តិកវង្ស ក្នុងប្រទេសកម្ពុជា ចាប់ផ្តើមកើតឡើងតាំងពី ព.ស. ២៣៩៧ រហូតដល់ ព.ស. ២៥០០ ត្រូវជា ១០៣ ឆ្នាំ ។ រវាង ១០៣ ឆ្នាំនេះ មានសម្តេចព្រះសង្ឃនាយកនៃធម្មយុត្តិកនិកាយ ៤ ព្រះអង្គគឺ:

ទី ១ – សម្តេចព្រះសុគន្ធាសំយកជាគណាធិបតី ទ៉ា ឆ ព.ស. ២៣៩៧

២ – សម្តេចព្រះមង្គលទេព្វាចារ្យ អៀម ,, ២៤៣៦

៣ – -ដ- ស៊ុក ,, ២៤៦៥

៤ – សម្តេចព្រះសុធម្មាធិបតី ស្រី ,, ២៤៨៥

ធម្មយុត្តិកប្រវត្តិ ក្នុងប្រទេសកម្ពុជា

សង្ខេបតែប៉ុណ្ណោះ ។